00835910



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 08 / 2012
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# **កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី**

## **សាធារណៈ**

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ច័ន្ទ ទី ១៣ ខែ សីហា ឆ្នាំ ២០១២

## **សវនាការលើអង្គសេចក្ដី - ថ្ងៃទី ៩៤**

រៀបចំដោយ: ឌុច ផារី និង Matteo CRIPPA

| **កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ** |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី និង ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោក ឌុច ផារី, លោក Matteo CRIPPA, លោក ដាវ អានសាន |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក វេង ហួត, លោក ច័ន្ទ តារារស្មី, លោក Dale Lysak, លោក Vincent DE WILDE D'ESTMAEL |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួនខាងក្រោម), នួន ជា, ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Jasper PAUW |

00835911



| |
|---|
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael KANAVAS |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោក ពេជ្រ អង្គ, លោកស្រី Elisabeth SIMONNEAU-FORT, លោក សំ សុគង់, លោក Ferdinand DJAMMEN NZEPA, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវន, លោកស្រី Beini YE, លោក វ៉េន ពៅ |
| សាក្សី៖ លោកវេជ្ជបណ្ឌិត គីម សមសាន្ត |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ |
| ផ្សេងៗ៖ លោក Jay GALIK |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២ | ចាប់ផ្ដើមម៉ោង៖ ០៩.២៥ | បញ្ចប់ម៉ោង៖ ១៣.៥០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| សម្រាកអាហារថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ៩.៥៥ | បញ្ចប់ម៉ោង៖ ១៣.៤៥ |
| សម្រាកពេលរសៀល | ចាប់ផ្ដើមម៉ោង៖ | បញ្ចប់ម៉ោង៖ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ៣៥ នាទី | | |

| **កិច្ចដំណើរការនីតិវិធី៖** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
| ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ | មេធាវីការពារក្ដី អៀង សារី | ០៩.៣៤ | ៩.៣៦ |
| ការស្ដាប់នូវការបំភ្លឺរបស់លោកវេជ្ជបណ្ឌិត គីម សមសាន្ត អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ៩.៣៧ | ៩.៥០ |
| ការពន្យាពេលនៃការចាប់ផ្ដើមសវនាការដោយសារសុខភាពរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ០៩.៥១ | ៩.៥៥ |
| ការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការដោយសារសុខភាពរបស់លោក អៀង សារី | អង្គជំនុំជម្រះ | ១៣.៤៤ | ១៣.៥០ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

**<u>ការស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់</u>**

ជនជាប់ចោទ អៀង សារី តាមរយៈមេធាវីរបស់គាត់ បានស្នើសុំលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែ បន្ទាប់ពីបានដាក់នូវលិខិតលះបង់សិទ្ធិក្នុងការចូលរួមសវនាការ ស្ថានភាពសុខភាពរបស់គាត់កាន់តែធ្ងន់ធ្ងរឡើង។ តាមរយៈមេធាវីរបស់គាត់ លោក អៀង សារី បានបង្ហាញថា គាត់មានបំណងលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ ប៉ុន្តែ គាត់មិនមានបំណងលះបង់សិទ្ធិក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីនោះទេ ហើយដោយសារស្ថានភាពសុខភាព គាត់មិនអាចចូលរួមកិច្ចដំណើរការនីតិវិធីនៅពេលនេះបានទេ ។ លោក អៀង សារី មានបំណងចូលរួមកិច្ចដំណើរការនីតិវិធីសវនាការក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សី អុង ថុងហឿង (TCW-490) និង ស្នូង ស៊ីគឿន ហៅ គង់ ឬ ធន (TCW-694) ។

**<u>ការស្តាប់នូវការបំភ្លឺរបស់លោកវេជ្ជបណ្ឌិត គឹម សមសាន្ត អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី</u>**

អង្គជំនុំជម្រះសួរសំណួរមួយចំនួនដល់លោកវេជ្ជបណ្ឌិត គឹម សមសាន្ត អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី ។ លោកវេជ្ជបណ្ឌិតបានបំភ្លឺថា លោក អៀង សារី ត្រូវការប្រើបន្ទប់ទឹកជាញឹកញាប់ ដូច្នេះហើយទើបធ្វើឲ្យគាត់មានអាការៈវិលមុខ ហើយលោក អៀង សារី បានអះអាងថា គាត់មិនមានលទ្ធភាពក្នុងការផ្តង់អារម្មណ៍តាមដានសវនាការបាននោះទេ។

**<u>ការពន្យាពេលនៃការចាប់ផ្តើមសវនាការដោយសារសុខភាពរបស់លោក អៀង សារី</u>**

ដោយសារស្ថានភាពសុខភាពរបស់លោក អៀង សារី មិនអាចធ្វើឲ្យគាត់ចូលរួមបាន អង្គជំនុំជម្រះសម្រេចពន្យាពេលការចាប់ផ្តើមដំណើរការសវនាការ ។ សវនាការនឹងបន្តនៅម៉ោង ១៣.៣០ នាទី ។

**<u>ការផ្អាកកិច្ចដំណើរការនីតិវិធីសវនាការដោយសារសុខភាពរបស់លោក អៀង សារី</u>**

បន្ទាប់ពីសម្រាកថ្ងៃត្រង់ លោក អៀង សារី នៅតែមានបញ្ហាសុខភាពដែលមិនអាចឲ្យគាត់ចូលរួមកិច្ចដំណើរការនីតិវិធីសវនាការបាន ហើយលោវេជ្ជបណ្ឌិត គឹម សមសាន្ត បានផ្តល់អនុសាសន៍ថា លោក អៀង សារី គួរតែត្រូវបានអនុញ្ញាតឲ្យសម្រាក ។ អង្គជំនុំជម្រះសម្រេចផ្អាកកិច្ចដំណើរការនីតិវិធីសវនាការ ដោយលើកទៅបន្តនៅថ្ងៃស្អែកវេលា ម៉ោង ៩.00 នាទី ហើយអង្គជំនុំជម្រះនឹងស្តាប់នូវសក្ខីកម្មរបស់សាក្សី អុង

ផុងហឿង (TCW-490) ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| (មិនមាន) | | | | | | | |

**<u>ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖</u>**

- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ នាំសាក្សី សួង ស៊ីគឿន ហៅ គង់ ឬ ធន (TCW-694) និង អ៊ុង ផុង ហឿន (TCW-490) ត្រឡប់ទៅកាន់ទីកន្លែងស្នាក់នៅរបស់គាត់ និងបង្គាប់ឱ្យនាំគាត់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២ ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ១៤ ខែ សីហា ឆ្នាំ ២០១២។

**<u>កាលបរិច្ឆេទបន្តសវនាការ៖</u>**

សវនាការនឹងបន្តនៅថ្ងៃ អង្គារ ទី ១៤ ខែ សីហា ឆ្នាំ ២០១២ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១២

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ឌុច ផារី** Matteo CRIPPA